*ការផ្សាយទី១ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨*

# ប្រភេទនៃរបបនយោបាយ និង ការអភិវឌ្ឍសេដ្ឋកិច្ច

អ៊ុន ឃាង*

## សេចក្តីផ្តើម

ការសិក្សាស្វែងរកពីមូលហេតុនៃការអភិវឌ្ឍសេដ្ឋកិច្ច គឺជាចំណុចដ៏គួរឱ្យចាប់អារម្មណ៍មួយសម្រាប់អ្នកសេដ្ឋកិច្ច អ្នកវិទ្យាសាស្រ្តសង្គម និងអ្នកបង្កើតគោលនយោបាយ តាំងពីយូរយារណាស់មកហើយ។ ប្រភេទនៃរបបនយោបាយ ត្រូវបានគេលើកឡើងថា ជាកត្តាចាំបាច់ក្នុងការជំរុញ ឬការធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ អ្នកវិភាគមួយចំនួនបានលើកឡើងថា របបប្រជាធិបតេយ្យ មានលទ្ធភាពក្នុងការផ្តល់នូវកំណើនសេដ្ឋកិច្ចឆាប់រហ័ស ស្របពេលដែលអ្នកវិភាគមួយចំនួនទៀតឱ្យតម្លៃទៅលើរបបផ្តាច់ការទៅវិញ។ ការលើកឡើងដែលផ្តល់តម្លៃឱ្យរបបផ្តាច់ការ រឹតតែមានភាពទាក់ទាញបន្ថែមទៀតជាមួយនឹងការរីកចម្រើនរបស់ប្រទេសចិននៅរយៈពេល ៤ ទសវត្សរ៍ចុងក្រោយនេះ។ ដូច្នេះ តើស្ថានភាពនៃការពិភាក្សាវែកញែកលើទំនាក់ទំនងរវាងប្រភេទនៃរបបនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច មានលក្ខណៈយ៉ាងដូចម្តេច? តើរបបនយោបាយប្រភេទណាដែលប្រទេសកំពុងអភិវឌ្ឍគួរតែកំណត់យក? អត្ថបទសង្ខេបនេះ នឹងផ្តល់ការពិភាក្សាវែកញែកតាមរយៈការលើកឡើងនូវចំណុចមួយចំនួនដូចតទៅ។ចំណុចទី១ នឹងគ្របដណ្តប់លើអំណះអំណាងគោលដែលឱ្យតម្លៃទៅលើរបបប្រជាធិបតេយ្យ។ ចំណុចទី២ នឹងលើកឡើងអំពីអំណះអំណាងគោលដែលឱ្យតម្លៃទៅលើរបបផ្តាច់ការ។ ចំណុចចុងក្រោយ នឹងផ្តោតទៅលើអំណះអំណាងដែលថា ប្រភេទនៃរបបនយោបាយមិនសំខាន់នោះទេ ហើយអ្វីដែលសំខាន់គឺគុណភាពនៃស្ថាប័នរដ្ឋាភិបាល។

## របបប្រជាធិបតេយ្យ របបផ្តាច់ការ និងការអភិវឌ្ឍសេដ្ឋកិច្ច

ទ្រឹស្តី និងការសិក្សាជាក់ស្តែង បានបង្ហាញថារបបប្រជាធិបតេយ្យជំរុញឱ្យមានការអភិវឌ្ឍ សេដ្ឋកិច្ចតាមបីរបៀប (Olson 1993; Acemoglu និង Robinson, 2012)។ របៀបទី១ ការអភិវឌ្ឍសេដ្ឋកិច្ចតម្រូវឱ្យមានការច្នៃប្រឌិត និងការវិនិយោគ ហើយដំណើរការទាំងនេះអាចរីកចម្រើនបានអាស្រ័យលើវត្តមាននៃការការពារទ្រព្យសម្បត្តិឯកជន។ ជាទូទៅ របបប្រជាធិបតេយ្យត្រូវបានគេជឿថាអាចផ្តល់នូវការការពារបែបនេះ ដោយសារតែមានប្រព័ន្ធត្រួតពិនិត្យបែបតុល្យភាព (checks and balances) ដែលត្រូវបានទ្រទ្រង់ដោយនីតិរដ្ឋ។ របៀបទី២ សេរីភាពសារព័ត៌មាន និងភាពប្រកួតប្រជែងក្នុងការបោះឆ្នោតនៅក្នុងរបបប្រជាធិបតេយ្យ ធ្វើឱ្យមន្ត្រីដែលជាប់ឆ្នោត មានការឆ្លើយតបយ៉ាងសកម្មទៅលើតម្រូវការរបស់អ្នកបោះឆ្នោត ហើយនេះនឹងជួយដល់ការលើកកម្ពស់តម្លាភាព ប្រសិទ្ធិភាព ភាពទទួលខុសត្រូវ និងគណនេយ្យភាពរបស់រដ្ឋាភិបាល។ របៀបទី៣ ជាមួយនឹងយន្តការនៃការផ្ទេរអំណាចដែលអាចនឹងព្យាករណ៍បាន របបប្រជាធិបតេយ្យនឹងធានានូវស្ថិរភាព និងភាពច្បាស់លាស់ផ្នែកនយោបាយ ដែលនឹងផ្តល់មកវិញជាលក្ខខណ្ឌទាក់ទាញសម្រាប់ការវិនិយោគ។

ទ្រឹស្តី និងការវិភាគជាក់ស្តែងក៏បានរកឃើញពីអត្ថប្រយោជន៍នៃរបបផ្តាច់ការផងដែរ ក្នុងការជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច។ របបផ្តាច់ការ មានស្វ័យភាព (សំដៅដល់ការការពារពីសំពាធរបស់ក្រុមដែលមានប្រយោជន៍ពាក់ព័ន្ធ)

* បណ្ឌិត អ៊ុន ឃាង ជាសាស្ត្រាចារ្យរង ផ្នែកវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យ Northern Illinois University និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា

*©រក្សាសិទ្ធិដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជាឡើយ*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

ហើយវានឹងផ្តល់ឱ្យរបបនេះនូវលទ្ធភាពក្នុងការបង្កើតគោលនយោបាយរួមសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងរយៈពេលយូរអង្វែង។ ជាក់ស្តែង រដ្ឋាភិបាលអាចគាបសង្កត់ទំនោរនៃការប្រើប្រាស់បរិភោគរបស់ប្រជាជនបច្ចុប្បន្ន ហើយវានឹងអាចជំរុញដល់ការសន្សំសំចៃសម្រាប់ការវិនិយោគនាពេលអនាគត។ មិនតែប៉ុណ្ណោះ ការគ្រប់គ្រងបែបផ្តាច់ការនឹងអាចផ្តល់ជាសណ្តាប់ធ្នាប់ និងស្ថិរភាពនយោបាយ ដោយសារតែលទ្ធភាពក្នុងការគ្រប់គ្រងការប៉ះទង្គិច និងការប្រឆាំងតវ៉ាផ្នែកនយោបាយ ហើយស្ថានភាពនេះក៏បានផ្តល់ជាទិដ្ឋភាពទាក់ទាញសម្រាប់ការវិនិយោគផងដែរ។ ការពិនិត្យឡើងវិញយ៉ាងលម្អិត ទៅលើអត្ថបទស្តីអំពីទំនាក់ទំនងរវាងប្រភេទនៃរបបនយោបាយ និងកំណើនសេដ្ឋកិច្ច និពន្ធដោយលោក Adam Przerworski (1995) មិនបានរកឃើញភស្តុតាងណាដែលអាចធ្វើការសន្និដ្ឋានបានឡើយ។ ភាពដែលមិនអាចធ្វើការសន្និដ្ឋានបាននេះ ត្រូវបានអះអាងថា កើតចេញពីអវត្តមាននៃការបែងចែកភាពខុសគ្នានៃរបបផ្សេងៗនៅក្នុងប្រភេទរបបនីមួយៗ ដោយផ្អែកទៅលើគុណភាពនៃស្ថាប័នរដ្ឋ។ នៅក្នុងការបែងចែកនៃប្រភេទរបបនីមួយៗ មានរបបដែលមានស្ថាប័នរដ្ឋខ្លាំង និងមានរបបដែលមានស្ថាប័នរដ្ឋខ្សោយ។ ទាំងរបបផ្តាច់ការ និងរបបប្រជាធិបតេយ្យ សុទ្ធតែមានអនុរបបចំនួន ២ នៅក្នុងនោះ គឺៈ របបផ្តាច់ការបែបបរិបាល (patronage authoritarianism) និងរបបផ្តាច់ការបែបការិយាធិបតេយ្យ (bureaucratic authoritarianism) ហើយនិងរបបប្រជាធិប-តេយ្យបែបបរិបាល (patronage democracy) និងរបបប្រជាធិបតេយ្យបែបការិយាធិបតេយ្យ (bureaucratic democracy) (Norris 2012)។

របបប្រជាធិបតេយ្យបែបបរិបាល មានរដ្ឋាភិបាលតំណាង ជាមួយនឹងការបោះឆ្នោតដែលមានការប្រកួតប្រជែង និងសេរីភាពនៃការបញ្ចេញមតិ ដោយប្រជាពលរដ្ឋអាចបង្ហាញពីតម្រូវការរបស់ខ្លួនតាមរយៈតំណាងរាស្ត្រដែលពួកគេបានបោះឆ្នោតឱ្យ ឬតាមរយៈគណបក្សនយោបាយ។ របបផ្តាច់ការបែបបរិបាល មិនមានទាំងរដ្ឋាភិបាលតំណាង ទាំងសេរីភាពនៃការបញ្ចេញមតិឡើយ។ ក្នុងន័យមួយទៀត ប្រជាពលរដ្ឋមិនអាចធ្វើការទាមទារទៅលើរដ្ឋាភិបាល និងការបោះឆ្នោតឡើយ ហើយបើទោះបីជាមាន ក៏វាគ្រាន់តែជាការបោកបញ្ឆោតនយោបាយតែប៉ុណ្ណោះ។ ប៉ុន្តែទាំងរបបប្រជាធិបតេយ្យបែបបរិបាល និងរបបផ្តាច់ការបែបបរិបាល មានទម្រង់គ្រប់គ្រងរួមបែបការិយាធិប-តេយ្យ។ ការិយាធិបតេយ្យនេះ គឺហ៊ុមព័ទ្ធដោយខ្សែ (clientelism) និងអំពើពុករលួយ។ ការផ្តល់សេវាសាធារណៈ ជាទូទៅមានលក្ខណៈមិនល្អ និងផ្តោតទាំងស្រុងលើបណ្តាញផ្ទាល់ខ្លួន និងការសូកប៉ាន់។ នីតិរដ្ឋ មានភាពទន់ខ្សោយ ហើយក្នុងករណីភាគច្រើន យុត្តិធម៌គឺជាការបំភ័ន្តសម្រាប់អ្នកក្រ។ ការជ្រើសរើសអ្នកកាន់តំណែងការិយាល័យ គឺផ្អែកទៅលើខ្សែ និងឋានៈសង្គម ហេតុនេះហើយបានជាអ្នកបម្រើសេវាសាធារណៈច្រើនតែមានជំនាញខ្សោយ មិនសកម្ម និងទទួលឥទ្ធិពលនយោបាយ។ អ្នកដឹកនាំ ទទួលបានការអនុវត្តតាមពីអ្នកក្រោមបង្គាប់ តាមរយៈបណ្តាញផ្ទាល់ខ្លួន និងមិនមែនតាមរយៈច្រកការិយាល័យត្រឹមត្រូវទេ។ ជាគោលអំណាចស្ថិតនៅក្រោមបុគ្គលមិនមែននៅក្នុងការិយាល័យផ្លូវការ ដែលការណ៍នេះនាំទៅរកឯកត្តបុគ្គលនីយកម្មនៃស្ថាប័នរដ្ឋ ជាជាងស្ថាប័ននីយកម្មនៃការិយាល័យរដ្ឋ។

អនុរបបមួយគូទៀតគឺ របបផ្តាច់ការបែបការិយាធិបតេយ្យ និងរបបប្រជាធិបតេយ្យបែបការិយាធិបតេយ្យ។ ទោះបីជារបបទាំងពីរប្រភេទនេះមានភាពខុសប្លែកក្នុងការគោរពសេរីភាពពលរដ្ឋ និងនយោបាយក្តី របបទាំងពីរនេះក៏មានលក្ខណៈដូចគ្នាទៅលើប្រសិទ្ធិភាពនៃស្ថាប័នរដ្ឋ ដែលអាចជួយសម្របសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ របបផ្តាច់ការបែបការិយាធិបតេយ្យ រួមមានរដ្ឋាភិបាលផ្តាច់ការ និងរដ្ឋាភិបាលពាក់កណ្តាលផ្តាច់ការ ដែលអនុវត្តនូវការរឹតត្បិតផ្សេងៗទៅលើមូលដ្ឋាននៃសិទ្ធិមនុស្ស។ របបពាក់កណ្តាលផ្តាច់ការបែបការិយាធិបតេយ្យ អាចមានប្រព័ន្ធពហុបក្ស ប៉ុន្តែគណបក្សកាន់អំណាច តែងតែទទួលបានជ័យជម្នះក្នុងការបោះឆ្នោត តាមរយៈមធ្យោបាយបំភ័ន្តភ្នែក (foul and fair means) (ឧទាហរណ៍៖ ប្រទេសសឹង្ហបុរី)។ របបផ្តាច់ការបែបការិយាធិបតេយ្យ អាចមានគណបក្សរដ្ឋតែមួយ (ឧទាហរណ៍៖ សាធារណរដ្ឋប្រជាមានិតចិន)។ របបប្រជាធិបតេយ្យបែបការិយាធិបតេយ្យ សំដៅទៅលើរបបដែលមានការគោរពយ៉ាងពេញលេញទៅលើសេរីភាពប្រជាពលរដ្ឋ និងនយោបាយ ជាមួយនឹងការបោះឆ្នោតដោយសេរី និង

យុត្តិធម៌ (ឧទាហរណ៍៖ ប្រទេសស៊ុយអែត)។ ទាំងរបបផ្តាច់ការបែបការិយាធិបតេយ្យ និងរបបប្រជាធិបតេយ្យបែបការិយាធិបតេយ្យ សុទ្ធតែមានលក្ខណៈសំខាន់មួយដូចគ្នា គឺមានស្ថាប័នរដ្ឋរឹងមាំ។ ស្ថាប័នទាំងនេះជាសមូហភាព បានបង្កើតរដ្ឋមួយដែលមានសមត្ថភាពរឹងមាំក្នុងការរក្សាសណ្តាប់ធ្នាប់សង្គម និងអធិបតេយ្យភាពជាតិ និងក្នុងការអនុវត្តគោលនយោបាយសាធារណៈ ដូចជាការប្រមូលចំណូល និងការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម។ របបប្រជាធិបតេយ្យបែបការិយាធិបតេយ្យ និងរបបផ្តាច់ការបែបការិយាធិបតេយ្យ ក៏មាននីតិរដ្ឋផងដែរទោះបីជាមានភាពខុសប្លែកគ្នារវាងរបបទាំងពីរប្រភេទនេះក៏ដោយ។ នីតិរដ្ឋមានភាពស្លួចស្ដើងនៅក្នុងរបបផ្ដាច់ការបែបការិយាធិបតេយ្យ។ នៅក្រោមប្រព័ន្ធច្បាប់នេះ ការអនុវត្តច្បាប់មានភាពត្រឹមត្រូវនៅក្នុងវិស័យពាណិជ្ជកម្ម និងសង្គម ប៉ុន្តែការអនុវត្តនេះមិនមានលក្ខណៈស្មើភាពទេនៅក្នុងវិស័យនយោបាយ។ ផ្ទុយទៅវិញ នីតិរដ្ឋមានភាពរឹងមាំនៅក្នុងរបបប្រជាធិបតេយ្យបែបការិយាធិបតេយ្យ។ នីតិរដ្ឋរឹងមាំ សំដៅដល់លក្ខណៈស្មើភាព ស័ក្តិសិទ្ធិភាព និងប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ទាំងក្នុងវិស័យពាណិជ្ជកម្ម និងនយោបាយ។ របបផ្តាច់ការបែបការិយាធិបតេយ្យ និងរបបប្រជាធិបតេយ្យបែបការិយាធិបតេយ្យ សុទ្ធតែមានការិយាធិបតេយ្យដែលស្របច្បាប់ និងប្រកបដោយហេតុផល។ មន្ត្រីនៃការិយាធិបតេយ្យ ត្រូវបានជ្រើសរើសតាមរយៈប្រព័ន្ធនៃគុណសម្បត្តិបុគ្គល (meritocratic)។ មន្ត្រីនៃការិយាធិបតេយ្យ ទទួលបានរង្វាន់តបស្នងតាមរយៈកញ្ចប់អត្ថប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែង។ មិនតែប៉ុណ្ណោះ មិនមានការជ្រៀតជ្រែកនយោបាយនៅក្នុងកិច្ចការការិយាល័យទេ។ ទ្រឹស្តីសំខាន់មួយទាក់ទងទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាសម្មតិកម្មរួមបញ្ចូលមួយ ដែលលើកឡើងថារាល់ប្រទេសកំពុងអភិវឌ្ឍ សុទ្ធតែមានលទ្ធភាពក្នុងការបង្កើនកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច។ គួរកត់សម្គាល់ថា លទ្ធភាពក្នុងការតាមឱ្យទាន់ តម្រូវឱ្យប្រទេសមួយមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់ និងក្នុងការលើកកម្ពស់ទីផ្សារប្រកួតប្រជែង។ ការប្រើប្រាស់បច្ចេកវិទ្យា និងការលើកកម្ពស់ទីផ្សារប្រកួតប្រជែង តម្រូវឱ្យរដ្ឋមានសមត្ថភាពរឹងមាំក្នុងការស្ថាបនា និងថែរក្សាឱ្យបាននូវផលិតផលសាធារណៈ (ដូចជាផ្លូវថ្នល់ អគ្គិសនី ការថែទាំសុខភាព និងការអប់រំ) និងនីតិរដ្ឋ។ រដ្ឋដែលមានសមត្ថភាពរឹងមាំនេះ មានវត្តមានតែនៅក្នុងរបបផ្តាច់ការបែបការិយាធិបតេយ្យ និងរបបប្រជាធិបតេយ្យបែបការិយាធិបតេយ្យប៉ុណ្ណោះ។

## សេចក្តីសន្និដ្ឋាន

អត្ថបទនានាបានបង្ហាញថាទាំងរបបផ្តាច់ការ និងរបបប្រជាធិបតេយ្យ ដែលរដ្ឋមានសមត្ថភាពរឹងមាំ អាចលើកកម្ពស់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ការកំណត់ថារបបមួយណាដែលគេឱ្យតម្លៃជាង គឺអាស្រ័យទៅលើគំនិតយល់ឃើញផ្សេងគ្នារបស់បុគ្គល។ គេអាចធ្វើការពិភាក្សាដោយផ្តល់តម្លៃទៅលើរបបផ្តាច់ការជាង ដោយផ្អែកទៅលើលក្ខខណ្ឌដោយឡែកនៃប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសមួយ។ សម្រាប់ប្រទេសខ្លះ ដោយសារតែពួកគេមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងជម្លោះផ្ទៃក្នុងរយៈពេលយូរអង្វែង ធ្វើឱ្យរបបប្រជាធិបតេយ្យមិនមានលក្ខណៈសាកសមចំពោះប្រទេសនោះទេ ព្រោះវាអាចបង្កើតអស្ថិរភាពនយោបាយ និងអាចនាំឱ្យកើតមានសង្គ្រាមស៊ីវិលម្តងទៀត។ សម្រាប់ប្រទេសខ្លះទៀតដោយសារតែភាពខុសគ្នានៃឫសគល់ប្រវត្តិសាស្ត្រ និងវប្បធម៌ របបប្រជាធិបតេយ្យជាទស្សនៈទានចម្លែកសម្រាប់ពួកគេ។ ក្នុងប្រទេសទាំងនេះ ការកសាងរបបប្រជាធិបតេយ្យ គួររង់ចាំពេលវេលាមួយក្រោយពេលដែលប្រទេសទាំងនោះ បានឈានទៅដល់កម្រិតណាមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមុនសិន។ ប៉ុន្តែវាចាំបាច់ក្នុងការលើកការពិភាក្សានេះ ដោយមិនអាចជៀសផុតពីការទទួលស្គាល់ថា មិនមែនគ្រប់របបផ្តាច់ការទាំងអស់ សុទ្ធតែមានសមត្ថភាពក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចឱ្យមាននិរន្តភាពនោះទេ។ ចាប់តាំងពីសង្គ្រាមលោកលើកទី២មក ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ បានបង្ហាញយ៉ាងច្បាស់ថាក្នុងចំណោមតំបន់ដែលកាន់របបផ្តាច់ការ មានតែរបបផ្តាច់ការបែបការិយាធិបតេយ្យ ដែលមានរដ្ឋមានសមត្ថភាពរឹងមាំទេ ដែលអាចលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចជារួម និងមាននិរន្តភាព។ អ្នកដឹកនាំនៃប្រទេសកំពុងអភិវឌ្ឍភាគច្រើនតែងតែប្រកាសពីភាពមិនទាក់ទងនៃរបបប្រជាធិបតេយ្យសម្រាប់

ប្រទេសពួកគេ ដោយសារតែអសមត្ថភាពរបស់របបនេះក្នុងការលើកកម្ពស់សន្តិភាព សណ្តាប់ធ្នាប់សង្គម និងការបង្កើតគោលនយោបាយបានលឿនរហ័ស ដែលជាធាតុផ្សំដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ អ្នកដឹកនាំទាំងនេះបានលើកឡើងថា អ្វីដែលប្រទេសកំពុងអភិវឌ្ឍត្រូវការ គឺរបបផ្តាច់ការ ឬពាក់កណ្តាលផ្តាច់ការ។ បញ្ហាប្រឈមធ្ងន់ធ្ងរមួយសម្រាប់អ្នកដឹកនាំនៃប្រទេសកំពុងអភិវឌ្ឍភាគច្រើន គឺថាទោះបីពួកគេមានគោលបំណងក្នុងការបង្កើតរបបផ្តាច់ការបែបការិយាធិបតេយ្យក៏ដោយ ប៉ុន្តែប្រទេសរបស់ពួកគេបានធ្លាក់ទៅក្នុងរបបផ្តាច់ការបែបបរិបាលទៅវិញ ដែលជាទម្រង់នៃរបបមួយដែលសម្រេចសម្រួលទៅជម្រុញទៅរករដ្ឋនៃការគៀបសង្កត់ និងភាពក្រីក្រក្នុងរយៈពេលវែង៕

## ឯកសារយោង

Acemoglu, Daron, and James A. Robinson. Why Nations Fail: The Origins of Power, Prosperity, and Poverty. Crown Business, 2013.

Evans, Peter B. Embedded Autonomy: States and Industrial Transformation. Princeton University Press, 2012.

Helpman, Elhanan. The Mystery of Economic Growth. Harvard University Press, 2009.

Huff, W. Gregg. "The developmental state, government, and Singapore's economic development since 1960." World Development 23, no. 8 (1995): 1421-1438.

Norris, Pippa. Making Democratic Governance Work: How Regimes Shape Prosperity, Welfare, and Peace. Cambridge University Press, 2012.

Olson, Mancur. "Dictatorship, democracy, and development." American Political Science Review 87, no. 3 (1993): 567-576.

Przeworski, Adam, Fernando Limongi, and Salvador Giner. "Political regimes and economic growth." In Democracy and Development, pp. 3-27. Palgrave Macmillan UK, 1995.

Skocpol, Theda, Peter Evans, and Dietrich Rueschemeyer.  Bringing The State Back In.  Cambridge University Press, 1999.

Cambodia Development Center
Cambodia Development Center (@cdcenter_kh)
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center
Building E, Univeristy of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.com | (+855) 16 616 951

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center